ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

ប្រធានគណៈមេធាវី
មេធាវី លី ច័ន្ទតុលា
ក្រុមប្រឹក្សាគណៈមេធាវី
១-មេធាវី កុយ នាម
២-មេធាវី ទេព បូផល
៣-មេធាវី ពេជ្រ សុរិយា
៤-មេធាវី ជុំ សុវណ្ណាលី
៥-មេធាវី ប៉ា ចូនគា
៦-មេធាវី ចេង ប៉េងហាប់
៧-មេធាវី យុង ផានិត
៨-មេធាវី ចៅ ប៊ុនហួន
៩-មេធាវី រស់ មុនិន្ទ:
១០-មេធាវី តែ ចំណាន
១១-មេធាវី ខូវ ចន្ថា
១២-មេធាវី ហុង គីមសួន
១៣-មេធាវី ឱុយ សុខសូលីដា
១៤-មេធាវី សួន ប៊ុនធឿន
១៥-មេធាវី កេង សុម៉ារតន៍
១៦-មេធាវី ពិន វណ្ណ:
១៧-មេធាវី ច័ន្ទ វិចិត្រ
១៨-មេធាវី ព្រហ្ម វិចិត្រសុតា
១៩-មេធាវី ណុប គុណាថុល
២០-មេធាវី យឹម ថាវី
២១-មេធាវី ឌឹម ចៅសេង
២២-មេធាវី លី សុខឡាយ
២៣-មេធាវី ស៊ុយ ឈុនហាក់
២៤-មេធាវី គង់ សំអុន
២៥-មេធាវី ហាក់ សៀកលី
២៦-មេធាវី គង់ សុគន្ធ្រា
២៧-មេធាវី គាន តារា
២៨-មេធាវី ហ៊ាង ហុង
២៩-មេធាវី ឈរ លីថៃ
៣០-មេធាវី ម៉ុម ពិសី
៣១-មេធាវី ទ្រី សំរស់
៣២-មេធាវី នួន ផានិត
៣៣-មេធាវី យុត កែវសុត្ថា

លេខ១០៥៣/គម/២១

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពីការបង្កើតក្រុមតេឡេក្រាមផ្លូវការរបស់ សមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា សូមជម្រាបជូនសមាជិក-សមាជិកាគណៈមេធាវីមេត្តាជ្រាបថា គណៈមេធាវីបានចេញសេចក្តីសម្រេចលេខ ២៨៥/សសគម/២១ ចុះថ្ងៃទី ១២ ខែមេសា ឆ្នាំ២០២១ ស្តីពីការបង្កើតក្រុមតេឡេក្រាមផ្លូវការរបស់សមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ដែលមានឈ្មោះថា "**សមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា (BAKC)**" និងមានរូបសញ្ញារបស់គណៈមេធាវីជាសម្គាល់ ក្នុងគោលបំណងបង្កើននូវប្រសិទ្ធភាពនៃការគ្រប់គ្រង ការប្រមូលផ្តុំសមាជិក-សមាជិកាតាមប្រព័ន្ធទំនាក់ទំនងបែបបច្ចេកវិទ្យាសម័យទំនើប ដើម្បីចែករំលែកព័ត៌មានវិជ្ជាជីវៈ ការជូនដំណឹង និងការឆ្លើយតបរាល់បញ្ហារបស់សហភាតា ប្រកបដោយភាពឆាប់រហ័ស។

តាមរយៈក្រុមតេឡេក្រាមផ្លូវការខាងលើនេះ គណៈមេធាវីអាចជូនដំណឹងឬផ្តល់ព័ត៌មានផ្លូវការដល់សហភាតាអំពីសេចក្តីសម្រេច សេចក្តីជូនដំណឹង សេចក្តីថ្លែងការណ៍ សេចក្តីអំពាវនាវ គោលនយោបាយ លិខិតនានា កម្មវិធីសិក្ខាសាលា កម្មវិធីបណ្តុះបណ្តាលផ្សេងៗ និងផ្សព្វផ្សាយអំពីសកម្មភាពរបស់គណៈមេធាវី ព្រមទាំងឆ្លើយតបបន្ទាន់ទៅនឹងបញ្ហាឬចម្ងល់នានាទាក់ទងនឹងការប្រកបវិជ្ជាជីវៈរបស់សហភាតា។

ចំពោះសមាជិក-សមាជិកាគណៈមេធាវីអាចផ្តល់ព័ត៌មាន ឬសំណូមពរ ឬសំណើផ្សេងៗមកកាន់គណៈមេធាវីតាមរយៈក្រុមតេឡេក្រាមនេះ មានជាអាទិ៍ ការរាយការណ៍អំពីភាពមិនប្រក្រតីនៃការប្រកបវិជ្ជាជីវៈមេធាវីឬការិយាល័យវិជ្ជាជីវៈមេធាវី ការស្នើសុំអន្តរាគមន៍ពាក់ព័ន្ធនឹងការប្រកបវិជ្ជាជីវៈមេធាវី ការចែករំលែកព័ត៌មាន ឯកសារ ឬតំណភ្ជាប់ផ្សេងៗដែលមានលក្ខណៈជាចំណេះដឹងនិងបទពិសោធន៍ ការលើកយោបល់ទូទៅអំពីបញ្ហាប្រឈម ការលើកនូវចម្ងល់ ការលើកជាយោបល់សម្រាប់មហាសន្និបាតប្រចាំឆ្នាំ និងការឃោសនាបោះឆ្នោតប្រធានឬក្រុមប្រឹក្សាគណៈមេធាវី។

ក្នុងសេចក្តីសម្រេចនេះ ក៏បានកំណត់អំពីសីលធម៌សម្រាប់ការជជែកពិភាក្សា ដូចជាត្រូវគោរពភាពចាស់ទុំនៃវ័យនិងភាពចាស់ទុំក្នុងវិជ្ជាជីវៈ ការណែនាំរបស់គណៈគ្រប់គ្រងក្រុមតេឡេក្រាម មិនត្រូវប្រើពាក្យពេចន៍ សំណេរ រូបភាព វីដេអូ ឯកសារផ្អែកទន់ ឬការជជែកពិភាក្សាមានលក្ខណៈប្រមាថមើលងាយដល់ស្ថាប័នគណៈមេធាវីនិងសមាជិកក្រុម មិនត្រូវប្រើពាក្យពេចន៍ សំណេរ រូបភាព វីដេអូ ឬឯកសារផ្អែកទន់បែបអាសអាភាស និងមិនត្រូវប្រើពាក្យពេចន៍អសុរោះ ជេរត្មះ ប្រទេចផ្តាសា។ លើសពីនេះ ពុំអនុញ្ញាតឱ្យសមាជិកក្រុមធ្វើសកម្មភាព



អគារកាច់ជ្រុងផ្លូវលេខ ១១២៩ និងផ្លូវលេខ ១៩៣០ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ប្រអប់សំបុត្រលេខ: ១៥៨៧, ទូរស័ព្ទ: ០២៣ ៦២២ ៧០៧០, Building at Corner of Street 1129 and 1930, Sangkat Phnom Penh Thmei, Khan Sen Sok, Phnom Penh. P.O. Box 1587, Tel: 023 622 70 70 Email: info@bakc.org.kh / Website: www.bakc.org.kh

និយាយ សរសេ ដាក់វីដេអូ ដាក់រូបភាព ដាក់ឯកសារផ្ទេកទន់ ឬការជជែកពិភាក្សា ដែលជាការប្រមាថដល់វិជ្ជាជីវៈមេធាវី ដែលប៉ះពាល់កិត្តិយសនិងសេចក្តីថ្លៃថ្នូររបស់ក្រសួង ស្ថាប័ន អង្គភាពនានា ឥស្សរសជន បុគ្គលនយោបាយ មន្ត្រី ចៅក្រម ឬព្រះរាជអាជ្ញា និងមិនអនុញ្ញាតឱ្យមានការជជែកដោយកំហឹង ការបង្កជម្លោះ ការលុបក្រុមតេឡេក្រាមចោល ការដកសមាជិកក្រុមដោយពុំមានការអនុញ្ញាត ការចាកចេញពីក្រុមដោយពុំមានការអនុញ្ញាត ការបំពានតាមបែបបច្ចេកវិទ្យា(Hack) ការបង្ករំខាន ការញុះញង់ ការគំរាមកំហែង ព្រមទាំងមិនអនុញ្ញាតឱ្យប្រកាន់និន្នាការនៃគណបក្សនយោបាយនិងការឃោសនាពីគណៈនយោបាយ។ បន្ថែមពីនេះ សមាជិកក្រុមមិនត្រូវផ្សព្វផ្សាយឬចែករំលែកបន្តនូវសកម្មភាពឬព័ត៌មានដែលមានក្នុងក្រុមតេឡេក្រាមនេះឡើយ។

ចំពោះទម្រង់នៃទំនាក់ទំនងក្នុងក្រុមតេឡេក្រាមនេះគឺត្រូវសរសេរជាខេមរភាសា ឬអាចប្រើជារូបភាព វីដេអូ ឬជាឯកសារផ្ទេកទន់ សម្រាប់ការជជែកពិភាក្សា និងការដាក់សំណើរផ្សេងៗ ដោយមិនអនុញ្ញាតឱ្យប្រើប្រាស់សារជាស្ទីកគ័រ(Stickers) ឬរូបភាពមានចលនា(GIF) ជាមធ្យោបាយនៃការជជែកពិភាក្សាឡើយ។

ដើម្បីឱ្យមានប្រសិទ្ធភាពស្របតាមគោលបំណងនៃការបង្កើតក្រុមតេឡេក្រាមនេះ គណៈមេធាវីបានសម្រេចតែងតាំងគណៈគ្រប់គ្រងក្រុមតេឡេក្រាមផ្លូវការនេះ ដោយមានសមាសភាពដូចជា ប្រធានគណៈមេធាវី អគ្គលេខាធិការ អគ្គលេខាធិការរង ប្រធាននិងអនុប្រធាននាយកដ្ឋានអធិការកិច្ច ប្រធាននិងអនុប្រធាននាយកដ្ឋានស្រាវជ្រាវ បោះពុម្ព និងផ្សព្វផ្សាយ និងប្រធាននិងអនុប្រធាននាយកដ្ឋានបុគ្គលិក និងរដ្ឋបាល។

អាស្រ័យហេតុនេះ សូមសមាជិក-សមាជិកាទទួលជ្រាបជាព័ត៌មាននិងសហការអនុវត្ត។

ថ្ងៃព្រហស្បតិ៍ ១ កើត ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែមិថុនា ឆ្នាំ២០២១

**ប្រធានគណៈមេធាវី**

មេធាវី លី ច័ន្ទតុលា